00231608

D99/3/22

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

សំណុំរឿងលេខ៖ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២)

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៣ ខែ តុលា ឆ្នាំ២០០៨

ភាគីបញ្ជូន៖ ការិយាល័យសហព្រះរាជអាជ្ញា

ភាសាដើម៖ អង់គ្លេស

ប្រភេទឯកសារ៖ សាធារណៈ

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការស្នើរបស់ អៀង សារី សុំដកគុណវុឌ្ឍិរបស់អ្នកមិនមែនជាភាគីនៃរឿងក្ដីនៅក្នុងបណ្ដឹងឧទ្ធរណ៍ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេចអ៊ាវ ហៅ ឌុច

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**បញ្ជូនទៅ៖**

**ការិយាល័យអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉ី ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្ដីជនត្រូវចោទ**

**ឈ្មោះ កាំង ហ្កេកអ៊ាវ៖**

លោក ការ សាវុត្ថ

លោក FranÇois ROUX

**មេធាវីការពារក្ដីជនមិនមែនជាភាគី**

**ឈ្មោះ អៀង សារី៖**

លោក អាង ឧត្ដម

លោក Michael KARNAVAS


ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / OCT / 2008
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fry

## ១. សង្ខេប និង ឧទ្ទេសករណ៍

១. អ្នកដាក់ពាក្យសុំឈ្មោះ អៀង សារី មិនមែនជាភាគីក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២) ប្រឆាំងនឹងឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច ("សំណុំរឿង១") ឡើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី អៀង សារី បានដាក់ពាក្យ[1]សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ Atonio Cassese និង សហការីរបស់លោកមិនឱ្យដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីទៅលើបញ្ហា សហកម្មនៃឧក្រិដ្ឋកម្មរួម ដែលស្នើឡើងដោយអង្គជំនុំជម្រះនេះ ។

២. សេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ លើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ "ឌុច"[2] ប្រកាសថា ជនត្រូវចោទពុំមានសិទ្ធិធ្វើអន្តរាគមន៍នៅក្នុងសំណុំរឿងណាមួយដែលខ្លួនមិនមែនជាភាគីឡើយ[3] ។ អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា: (១) វិធានផ្ទៃក្នុង និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានចែងអំពីសិទ្ធិសម្រាប់តតីយជនក្នុងការធ្វើអន្តរាគមន៍ក្នុងសំណុំរឿងឡើយ[4] ។ (២) សហព្រះរាជអាជ្ញាមិនបានរកឃើញថា អៀង សារី ជាសមាជិកនៃក្រុមមនុស្សដែលចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមឡើយ

[1] ពាក្យសុំរបស់លោក អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ កាសេស៊ី (Cassese) និងសមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធនិងគណៈកម្មាធិការនិពន្ធនិងនៃទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិពីការដាក់សារណាជាលាយលក្ខណ៍អក្សររបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២) ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០០៨ [ចាប់ពីពេលនេះទៅហៅថា "ពាក្យសុំ"] ។

[2] សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២) ថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨ [ចាប់ពីពេលនេះតទៅហៅថា "សេចក្តីសម្រេច"] ។

[3] សេចក្តីសម្រេច កថាខណ្ឌ ១៤ ។

[4] សេចក្តីសម្រេច កថាខណ្ឌ ៩ ។

...នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ[5] ហើយ (៣) អៀង សារី នឹងមានលទ្ធភាពក្នុងការតទល់នឹងការអនុវត្តន៍នូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដែលក្នុងសំណុំរឿងនោះ គាត់គឺជាភាគីនៃរឿងក្តី[6] ។ ជាពិសេស អង្គបុរេជំនុំជម្រះប្រកាសថា អៀង សារី ពុំមានឋានៈក្នុងការផ្តល់ទឡ្ហីករណ៍អំពីជំហររបស់គាត់ឡើយនៅក្នុង សំណុំរឿង១ ពីព្រោះគាត់ពុំមែនជាភាគីក្នុងរឿងក្តីនោះឡើយ[7] ។

៣. សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវពាក្យសុំនេះថា មិនអាចទទួលយកបានពីព្រោះអ្នកដាក់ពាក្យសុំនេះមិនមែនជាភាគីនៅក្នុងសំណុំរឿង១ ហើយគ្មានឋានៈនៅក្នុងដំណើរការនីតិវិធីដែលកំពុងអនុវត្តបច្ចុប្បន្ននេះទេ ។ សហព្រះរាជអាជ្ញាលើកសំណើនេះ ដោយផ្អែកទៅលើអំណាចនៃសេចក្តីសម្រេចកន្លងមកនេះ ព្រមទាំងសនិទានភាពជាក់ស្តែង ។ ដោយសារ អៀង សារី មិនមែនជាភាគីនៃសំណុំរឿង១ ដូច្នេះគឺគាត់គ្មានឋានៈក្នុងការលើកឡើងនូវការទាមទារដែលទាក់ទងនឹងសំណុំរឿងនេះ ។ ពាក្យសុំរបស់គាត់ពុំទាក់ទង ហើយជាផលវិបាកសេចក្តីសង្កេតរបស់គាត់មិនគួរយកទៅពិចារណាឡើយ ។

៤. ប៉ុន្តែប្រសិនបើ អង្គបុរេជំនុំជម្រះសម្រេចផ្តល់នូវឋានៈដល់ អៀង សារី ហើយយល់ស្របទទួលយកទៅពិចារណានូវទឡ្ហីករណ៍របស់គាត់អំពីអង្គសេចក្តីនៃពាក្យសុំរបស់គាត់ សហព្រះរាជអាជ្ញាសូមស្នើសុំការអនុញ្ញាតដើម្បីកែប្រែចម្លើយតបនេះវិញដើម្បីតទល់នឹងទឡ្ហីករណ៍ទាំងនោះ ។

[5] សេចក្តីសម្រេច កថាខណ្ឌ ១៣ ។

[6] សេចក្តីសម្រេច កថាខណ្ឌ ១២ ។

[7] សេចក្តីសម្រេច កថាខណ្ឌ ៨ ។

00231611

D99/3/22

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២)

**២. សំណើ**

៥. ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវពាក្យសុំនេះ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT